# ក្មេងសាលាមត្តេយ្យចូលចិត្តរៀនសូត្រ

## តើសាលាមត្តេយ្យជាអ្វី?

សាលាមត្តេយ្យគឺជាកម្មវិធីអប់រំសម្រាប់កុមារ មុនពេលពួកគេចាប់ផ្ដើមចូលរៀន។

កម្មវិធីសិក្សាថ្នាក់មត្តេយ្យត្រូវបានបង្រៀនដោយគ្រូដែលមានសញ្ញាបត្រសាកលវិទ្យាល័យ។ នៅសាលាមត្តេយ្យ កូនរបស់អ្នកនឹងអភិវឌ្ឍជំនាញសំខាន់ៗដើម្បីជួយរៀបចំពួកគេឱ្យចូលសាលារៀន។

## ហេតុអ្វីបានជាកម្មវិធីសិក្សាថ្នាក់មត្តេយ្យមានសារៈសំខាន់សម្រាប់កូនរបស់ខ្ញុំ?

កុមារដែលចូលរៀនសាលាមត្តេយ្យ អភិវឌ្ឍជំនាញដែលជាមូលដ្ឋានគ្រឹះសម្រាប់ការរៀនសូត្រនាពេលអនាគត ដូចជាការអាន ការរៀនរាប់ និងស្គាល់លេខ និងវិធីដោះស្រាយបញ្ហានានា។ កូនរបស់អ្នកនឹងរៀនតាមរយៈការលេង ដែលការស្រាវជ្រាវបង្ហាញថាជាវិធីសាស្ត្រល្អបំផុតក្នុងការបង្រៀនកុមារនៅវ័យក្មេង។ នៅសាលាមត្តេយ្យ កូនរបស់អ្នកនឹងបង្កើតមិត្តភក្តិថ្មី ហើយបង្កើតទំនុកចិត្ត និងមានឯករាជ្យភាព។

## តើអ្នកណាផ្ដល់កម្មវិធីសិក្សាថ្នាក់មត្តេយ្យ?

កម្មវិធីសិក្សាថ្នាក់មត្តេយ្យមានផ្ដល់នៅតាមមណ្ឌលថែទាំកុមារពេលថ្ងៃភាគច្រើន ហើយក៏មាននៅតាមសេវាកម្មថ្នាក់មត្តេយ្យដាច់ដោយឡែកផងដែរ។

## តើខ្ញុំជ្រើសរើសសាលាមត្តេយ្យល្អបំផុតសម្រាប់កូនរបស់ខ្ញុំយ៉ាងដូចម្ដេច?

វាជាការល្អក្នុងការពិនិត្យមើលថា តើសេវាកម្មនេះផ្ដល់ជូនកម្មវិធីសិក្សាថ្នាក់មត្តេយ្យដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលឬអត់ - រកមើលសញ្ញាបត្រ ‘សាលាមត្តេយ្យឧបត្ថម្ភថវិកាដោយរដ្ឋាភិបាល’ ដែលដាក់បង្ហាញនៅតាមសេវាកម្មនោះ។

រដ្ឋាភិបាលវាយតម្លៃគុណភាពនៃសេវាកម្មថ្នាក់មត្តេយ្យ និងសេវាកម្មថែទាំកុមារពេលថ្ងៃក្រោមប្រព័ន្ធមួយហៅថា ក្របខ័ណ្ឌគុណភាពថ្នាក់ជាតិ ហើយផ្ដល់សេវាកម្មនីមួយៗនូវចំណាត់ថ្នាក់គុណភាព។ សេវាកម្មទាំងអស់ត្រូវតែដាក់បង្ហាញចំណាត់ថ្នាក់របស់ពួកគេ។ អ្នកអាចស្នើសុំសេវាកម្មដើម្បីបង្ហាញអ្នក ឬប្រាប់អ្នកពីចំណាត់ថ្នាក់ដែលពួកគេបានទទួល។

វិធីល្អបំផុតដើម្បីធ្វើឱ្យប្រាកដថាសេវាកម្មនេះត្រឹមត្រូវសម្រាប់គ្រួសាររបស់អ្នក គឺអញ្ជើញទៅកាន់សេវាកម្មថែទាំកុមារពេលថ្ងៃ ឬសាលាមត្តេយ្យ ពិនិត្យមើល ហើយនិយាយជាមួយពួកគ្រូដើម្បីឱ្យបានយល់ដឹងពីកម្មវិធីថ្នាក់មត្តេយ្យអ្វីខ្លះ ដែលអាចផ្ដល់សម្រាប់កូនរបស់អ្នក។

## តើមានអ្វីកើតឡើង ប្រសិនបើកូនរបស់ខ្ញុំមិនទាន់អាចនិយាយភាសាអង់គ្លេសបាននៅឡើយ?

គ្រូបង្រៀនថ្នាក់មត្តេយ្យដាក់បញ្ចូលកុមារទាំងអស់នៅក្នុងកម្មវិធី ដូច្នេះកុមារដែលមិនចេះនិយាយភាសាអង់គ្លេស នឹងមានឱកាសដើម្បីលេង និងរៀនដូចកុមារឯទៀតដែរ។

សាលាមត្តេយ្យខ្លះក៏អាចមានអ្នកអប់រំដែលចេះពីរភាសា ដែលអាចផ្ដល់ជំនួយបន្ថែមសម្រាប់កុមារដែលនិយាយភាសាអង់គ្លេសតិចតួច ឬមិនចេះនិយាយភាសាអង់គ្លេស។



VICTORIA State Government | Education and Training

## តើសាលាមត្តេយ្យមានតម្លៃប៉ុន្មាន?

រដ្ឋាភិបាលផ្តត់ផ្គង់ថវិកាដល់កុមារទាំងអស់ដើម្បីចូលរៀនសាលាមត្តេយ្យចំនួន១៥ម៉ោងក្នុងមួយសប្តាហ៍ ក្នុងឆ្នាំមុនចូលសាលា។ សេវាកម្មភាគច្រើន គិតថ្លៃបន្ថែមលើថវិកាដែលរដ្ឋាភិបាលបានផ្តត់ផ្គង់។

គ្រួសារខ្លះអាចនឹងទទួលបានប្រាក់ឧបត្ថម្ភដើម្បីជួយបង់លើតម្លៃបន្ថែមនោះ ឧទាហរណ៍ គ្រួសារដែលមានប័ណ្ណថែទាំសុខភាព ឬទិដ្ឋាការមនុស្សធម៌។ សូមនិយាយទៅកាន់សេវាកម្មថ្នាក់មត្តេយ្យសម្រាប់ព័ត៌មានបន្ថែម។

## តើខ្ញុំត្រូវចុះឈ្មោះកូនរបស់ខ្ញុំនៅសាលាមត្តេយ្យយ៉ាងដូចម្តេច?

ប្រសិនបើអ្នកដឹងថាសាលាមត្តេយ្យមួយណាដែលអ្នកចង់ឱ្យកូនរបស់អ្នកទៅ អ្នកអាចទាក់ទងមកពួកគេដើម្បីចុះឈ្មោះ។ សាលាសង្កាត់ក្នុងតំបន់ជាច្រើនមានប្រព័ន្ធគម្រោងការកណ្តាលដើម្បីចុះឈ្មោះចូលរៀនសាលាមត្តេយ្យ ដូច្នេះអ្នកអាចទាក់ទងមកសាលាសង្កាត់ក្នុងតំបន់របស់អ្នកដើម្បីចុះឈ្មោះក្នុងកម្មវិធីសិក្សាថ្នាក់មត្តេយ្យក្នុងតំបន់របស់អ្នក ឬសួរគិលានុប្បដ្ឋាកសុខភាពមាតា និងទារករបស់អ្នក។

សាលាមត្តេយ្យភាគច្រើនចុះឈ្មោះកុមារនៅពាក់កណ្តាលឆ្នាំសម្រាប់ឆ្នាំបន្ទាប់។ សាលាមត្តេយ្យជាច្រើនមានបញ្ជីរង់ចាំ ដូច្នេះវាជាគំនិតល្អដែលត្រូវចុះឈ្មោះកូនរបស់អ្នកឱ្យបានឆាប់ ដើម្បីមានឱកាសល្អបំផុតទទួលបានកន្លែងមួយនៅសាលាមត្តេយ្យដែលអ្នកចូលចិត្ត។

## ស្វែងយល់បន្ថែមទៀត

### វ៉ិបសៃថ៍

ទទួលបានដំបូន្មានស្តីអំពីការស្វែងរកសាលាមត្តេយ្យត្រឹមត្រូវសម្រាប់គ្រួសាររបស់អ្នក៖

www.education.vic.gov.au/parents/childcare-kindergarten/Pages/default.aspx

ស្វែងរកសាលាមត្តេយ្យក្នុងតំបន់របស់អ្នក៖

www.education.vic.gov.au/findaservice/Home.aspx

### ទូរស័ព្ទ

| | |
|---|---|
| តំបន់ភាគខាងជើងឆៀងខាងកើតរដ្ឋវិចថូរៀ (North eastern Victoria) | 1300 333 231 |
| តំបន់ភាគខាងជើងឆៀងខាងលិចរដ្ឋវិចថូរៀ (North western Victoria) | 1300 338 691 |
| តំបន់ភាគខាងត្បូងឆៀងខាងកើតរដ្ឋវិចថូរៀ (South eastern Victoria) | 1300 338 738 |
| តំបន់ភាគខាងត្បូងឆៀងខាងលិចរដ្ឋវិចថូរៀ (South western Victoria) | 1300 333 232 |

ដើម្បីទទួលបានជំនួយជាភាសារបស់អ្នក៖

- ទូរស័ព្ទទៅសេវាកម្មថ្នាក់ជាតិ បកប្រែភាសាសរសេរ និងភាសានិយាយ (TIS) on 131 450
- ស្នើសុំឱ្យពួកគេហៅលេខទូរស័ព្ទសម្រាប់តំបន់របស់អ្នក (សូមមើលខាងលើ)
- ពួកគេនឹងនៅជាប់ទូរស័ព្ទ ហើយបកប្រែជូនអ្នក។